រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៦៧១៧ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
## ស្តីពី
## សិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទសម្រាប់មន្ត្រីនគរបាលជាតិកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៧៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្សចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣០៣ អនក្រ.បក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយមហាផ្ទៃនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ ស្តីពីការដំឡើងថ្នាក់ស្មើនាយកដ្ឋានដល់អង្គភាពថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៧៦ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០២៤ ស្តីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីសិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទសម្រាប់មន្ត្រីនគរបាលជាតិកម្ពុជា ដើម្បីពង្រឹងការគោរពវិន័យ ការធានានិរន្តរភាពការងារ ការគ្រប់គ្រង ការលើកកម្ពស់ប្រសិទ្ធភាពការងារ និងសុខុមាលភាពជូនមន្ត្រីនគរបាលជាតិកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរាល់ការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូនមន្ត្រីនគរបាលជាតិកម្ពុជា។

## ជំពូកទី២

## សិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទសម្រាប់មន្ត្រីនគរបាលជាតិកម្ពុជា

**ប្រការ៣.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូន៖

១- អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាននានា និងប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែលចំណុះក្រសួងមហាផ្ទៃ។

២- មន្ត្រីនគរបាលជាតិកម្ពុជាដែលស្នើសុំច្បាប់ឈប់ដើម្បីចេញទៅក្រៅប្រទេស។

**ប្រការ៤.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រគល់សិទ្ធិតាមឋានានុក្រមក្នុងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូនថ្នាក់ដឹកនាំក្រសួង និងប្រធានអង្គភាពចំណុះ ដូចខាងក្រោម៖

១- រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកអគ្គនាយកដ្ឋានធនធានមនុស្ស មានសិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូនមន្ត្រីនគរបាលជាតិកម្ពុជា ចាប់ពី១២(ដប់ពីរ)ថ្ងៃឡើងនៃថ្ងៃធ្វើការ។

២- អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ មានសិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូនប្រធានសេនាធិការដ្ឋាន ប្រធាននាយកដ្ឋានកណ្តាល ប្រធាននាយកដ្ឋាន ប្រធានអង្គភាពស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ និងមន្ត្រីនគរបាលជាតិកម្ពុជាក្រោមឱវាទ ត្រឹម១១(ដប់មួយ)ថ្ងៃចុះនៃថ្ងៃធ្វើការ។

៣- អគ្គនាយកនៃអគ្គនាយកដ្ឋាននានា និងប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែល ចំណុះក្រសួងមហាផ្ទៃ មានសិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូនមន្ត្រីនគរបាលជាតិកម្ពុជាក្រោមឱវាទ ត្រឹម១១(ដប់មួយ)ថ្ងៃចុះនៃថ្ងៃធ្វើការ។

៤- ប្រធានសេនាធិការដ្ឋាន និងប្រធាននាយកដ្ឋានកណ្តាលចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ មានសិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូនមន្ត្រីនគរបាលជាតិកម្ពុជាក្រោមឱវាទ ត្រឹម៥(ប្រាំ)ថ្ងៃចុះនៃថ្ងៃធ្វើការ។

៥- ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋាននានា និងអង្គភាពថ្នាក់ប្រហាក់ប្រហែល ព្រមទាំងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានសិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូនមន្ត្រីនគរបាលជាតិកម្ពុជា ក្រោមឱវាទ ត្រឹម៤(បួន)ថ្ងៃចុះនៃថ្ងៃធ្វើការ។

៦- នាយកសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម នាយកសាលានគរបាលជាតិភូមិភាគ អធិការនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែន គោក-ទឹក ប្រធានអង្គភាពបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រនៃនាយកដ្ឋាននគរបាលការពារព្រំដែនទឹក នាយកសាលាហ្វឹកហ្វឺនជំនាញនគរបាលការពារព្រំដែននៃនាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន ប្រធានស្នាក់ការប្រឆាំងចារកម្មប្រចាំរាជធានី ខេត្តចំណុះការិយាល័យប្រឆាំងចារកម្មនៃនាយកដ្ឋាន ចារកម្ម ប្រធានស្នាក់ការប្រចាំតំបន់នៃនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម ប្រធានអង្គភាព នគរបាលទេសចរណ៍នៃនាយកដ្ឋាននគរបាលទេសចរណ៍ ប្រធានអង្គភាពនគរបាលការពារបេតិកភណ្ឌ នៃនាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ ប្រធានសាខាលិខិតឆ្លងដែនប្រចាំតំបន់នៃនាយកដ្ឋាន លិខិតឆ្លងដែន នាយប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ នាយប៉ុស្តិ៍នគរបាលច្រកទ្វារ ព្រំដែនអន្តរជាតិ និងនាយប៉ុស្តិ៍នគរបាលកំពង់ផែច្រកទ្វារអន្តរជាតិ មានសិទ្ធិអនុញ្ញាតច្បាប់ឈប់ គ្រប់ប្រភេទជូនមន្ត្រីនគរបាលជាតិកម្ពុជាក្រោមឱវាទ ត្រឹម២(ពីរ)ថ្ងៃចុះនៃថ្ងៃធ្វើការ។

៧- នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ មានសិទ្ធិអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូនមន្ត្រី នគរបាលជាតិកម្ពុជាក្រោមឱវាទ ត្រឹម១(មួយ)ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ៥.-**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវដាក់ពាក្យស្នើសុំច្បាប់ឈប់គ្រប់ប្រភេទ តាមឋានានុក្រមនៃមន្ត្រី មានសមត្ថកិច្ច ដូចបានកំណត់ក្នុងប្រការ៤ នៃប្រកាសនេះ ដើម្បីឈប់សម្រាក ដូចខាងក្រោម៖

១- ច្បាប់ឈប់ប្រចាំឆ្នាំ។

២- ច្បាប់ឈប់រយៈពេលខ្លី ដោយបញ្ជាក់អំពីមូលហេតុឬលិខិតបញ្ជាក់ផ្សេងៗ។

៣- ច្បាប់ឈប់សម្រាកលំហែមាតុភាព ដោយភ្ជាប់មកជាមួយលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច។

៤- ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ដោយភ្ជាប់មកជាមួយលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច។

៥- ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ដោយបញ្ជាក់អំពីមូលហេតុឬលិខិតបញ្ជាក់ផ្សេងៗ។

**ប្រការ៦.-**

អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាននានា និងប្រធាន អង្គភាពថ្នាក់ប្រហាក់ប្រហែល ត្រូវដាក់ពាក្យស្នើសុំច្បាប់ឈប់គ្រប់ប្រភេទមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រួចបញ្ជូនសំណុំឯកសារសុំច្បាប់ មកអគ្គនាយកដ្ឋានធនធានមនុស្ស ឱ្យបានមុនរយៈពេល ១០(ដប់) ថ្ងៃ លើកលែងតែករណីប្រធានសក្តិ គ្រោះថ្នាក់ ឬមានជំងឺបន្ទាន់។

មន្ត្រីនគរបាលជាតិកម្ពុជា ដែលស្នើសុំច្បាប់ឈប់គ្រប់ប្រភេទចាប់ពី១២(ដប់ពីរ) ថ្ងៃឡើងនៃថ្ងៃធ្វើការ ត្រូវដាក់ពាក្យស្នើសុំតាមឋានានុក្រមនៃមន្ត្រីមានសមត្ថកិច្ច រួចបញ្ជូនសំណុំឯកសារសុំច្បាប់ មកអគ្គនាយកដ្ឋាន ធនធានមនុស្ស ឱ្យបានមុនរយៈពេល ១០(ដប់)ថ្ងៃ លើកលែងតែករណីប្រធានសក្តិ គ្រោះថ្នាក់ ឬមានជំងឺបន្ទាន់។

**ប្រការ៧.-**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋាននានា និងអង្គភាព ថ្នាក់ប្រហាក់ប្រហែល ចំណុះក្រសួងមហាផ្ទៃ ត្រូវចុះកាលបរិច្ឆេទនៃការចាប់ផ្តើមឈប់ និងការចូលបម្រើ ការងារវិញនូវរាល់លិខិតអនុញ្ញាតឱ្យឈប់គ្រប់ប្រភេទ។

**ប្រការ៨.-**

អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋាននានា និងអង្គភាពថ្នាក់ប្រហាក់ប្រហែល ចំណុះក្រសួងមហាផ្ទៃ ត្រូវធ្វើរបាយការណ៍បូកសរុបប្រចាំខែនូវការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទដែលបានអនុញ្ញាតរួចហើយ រួចបញ្ជូនមកអគ្គនាយកដ្ឋានធនធានមនុស្ស ក្រសួងមហាផ្ទៃ។

**ប្រការ៩.-**

មន្ត្រីនគរបាលជាតិកម្ពុជា ដែលទទួលបានការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទ ត្រូវស្ថិតក្នុងស្ថានភាពផ្តាច់ចេញពីការងាររហូតដល់ថ្ងៃចូលបម្រើការងារវិញ។ ក្នុងករណីចាំបាច់នៃការងារ ប្រធានអង្គភាពឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិអញ្ជើញមន្ត្រីនគរបាលជាតិកម្ពុជាដែលទទួលបានការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទឱ្យចូលបម្រើការងារវិញមុនពេលកំណត់។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ចន្ទ. ៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០២៤
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អគ្គបណ្ឌិតសភាចារ្យ ស សុខា**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ